មជ្ឈមណ្ឌលឯកសារកម្ពុជា

**ការបង្ហាត់បង្រៀនប្រល័យពូជសាសន៍ ៖ គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ**
**វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិស្តីពីការបង្រៀនប្រវត្តិសាស្ត្រ**
**កម្ពុជាប្រជាធិបតេយ្យនៅថ្នាក់មធ្យមសិក្សា**

២៩ មិថុនា-៧ កក្កដា ២០០៩

បណ្ណាល័យព្រឹទ្ធសភា ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**អត្ថបទៈ រីលី ផតថិត «ការស្វែងយល់ពីបញ្ហាផ្សេងៗ:**
**កម្មវិធីសិក្សាហូឡូខសនិងការសិក្សាពីសង្គម»** ***ទ្រឹស្តី៣០ចំណុចនិងការស្រាវជ្រាវផ្នែកអប់រំសង្គម***
**លេខ២៤, ទំព័រ ៥៤១-៥៦២ (២០០២)**

*កំណត់ចំណាំៈ ពាក្យមួយចំនួនត្រូវបានពិនិត្យនិងផ្លាស់ប្តូរដើម្បីសម្រួលដល់ការបកប្រែ ។*

# ការស្វែងយល់ពីស្ថានភាពនិងអារម្មណ៍តួអង្គនៅក្នុងប្រវត្តិសាស្ត្រ (Historical Empathy) ការគិតពិចារណាបែបប្រវត្តិសាស្ត្រ(Historical Thinking) និងសៀវភៅណែនាំរបស់សារមន្ទីរនៃការចងចាំហូឡូខស របស់សហរដ្ឋអាមេរិក (USHMM)

ការសិក្សាពីរបៀបដែលកុមារគិតឬស្វែងយល់ប្រវត្តិសាស្ត្រ ជះឥទ្ធិពលទៅលើការព្យាយាមស្វែងយល់ពីស្ថានភាពនិងអារម្មណ៍របស់តួអង្គក្នុងប្រវត្តិសាស្ត្រ (Historical Empathy) ព្រមទាំងទស្សនៈរបស់តួអង្គទាំងនោះ ។ [....] សេចក្តីព្យាយាមស្វែងយល់ពីស្ថានភាពក្នុងអតីតកាល (Historical Empathy) ជាដំណើរការមួយអាចទទួលជោគជ័យទៅបានអាស្រ័យដោយការគិតពិចារណា បែបប្រវត្តិសាស្ត្រ ។ ការស្វែងយល់ពីអតីតកាលនេះរួមផ្សំដោយសមាសធាតុបួនសំខាន់ គឺ សេចក្តីផ្តើមនិងការវិភាគទៅលើព្រឹត្តិការណ៍សំខាន់ៗ ខ្លឹមសារ និងកាលប្បវត្តិ ភស្តុតាង និងការពិពណ៌នារឿងរ៉ាវ។ ទោះជាយ៉ាងនេះក៏ដោយ យើងរកឃើញថាការពិចារណាទៅលើប្រវត្តិសាស្ត្រនេះ [....] បានបង្ហាញនូវបញ្ហាប្រវត្តិសាស្ត្រមួយចំនួនប្រឈមមុខដោយបុគ្គលសំខាន់ៗដែលមានសកម្មភាព និងគោលបំណង អាចធ្វើឲ្យសិស្សមានសមត្ថភាពធ្វើការវិភាគ និងប្រើប្រាស់ ដើម្បីស្តាបនាការពិពណ៌នាប្រវត្តិសាស្ត្រយ៉ាងត្រឹមត្រូវ (ឧទាហរណ៍ៈ ការសម្រេចចិត្តរបស់ទ្រូមែន ដើម្បីទម្លាក់

គ្រាប់បែក ឬផែនការសម្រាលរបស់ ណេវីល ឆេមប៊ើលែន) ។ ការពិពណ៌នាសង្ខេប (ឬការពិពណ៌នាពីរឿងរ៉ាវ) នៃព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនេះ ធ្វើឲ្យសិស្សមានការយកចិត្តទុកដាក់ និងផ្តោតសំខាន់ទៅលើសកម្មភាពរបស់តួអង្គប្រវត្តិសាស្ត្រសំខាន់ៗ និងចង់ធ្វើការពិនិត្យទៅលើឯកសារ ដែលទាក់ទងទៅនឹងសកម្មភាពទាំងនោះ ។ ទោះជាយ៉ាងណាក៏ដោយ យើងអាចពង្រីកចំណេះដឹងប្រវត្តិ-សាស្ត្រ ដោយធ្វើការបញ្ចូលព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ។ ឧទាហរណ៍ ស្ថានភាពនយោបាយរបស់ហូឡូខស ធ្វើឲ្យសិស្សស្វែងយល់ពីតួអង្គសំខាន់ៗ ជាពិសេសតួនាទីរបស់ អាដូហ្វ អ៊ីត្លែរ ប៉ុន្តែតួអង្គផ្សេងៗទៀត ដូចជា ភាពសកម្មនិងអសកម្មរបស់អ្នកផ្សំគំនិត អ្នកដែលបានឃើញព្រឹត្តិការណ៍ និងប្រជាជនសាមញ្ញ ក៏ដើរតួសំខាន់ក្នុងការសិក្សាពីហូឡូខសដែរ ។ លើសពីនោះទៅទៀត គ្រូអាចបង្រៀនបន្ថែមពីការគ្រប់គ្រងរបស់ណាស៊ីនៅជិតទាន់សង្គ្រាម ដែលជាចំណុចសំខាន់មួយនៅក្នុងប្រវត្តិសាស្ត្រហូឡូខស ។ សរុបសេចក្តីមក សិស្សមិនគួរផ្តោតការយកចិត្តទុកដាក់តែទៅលើបុគ្គល ឬតួអង្គនៅក្នុងប្រវត្តិសាស្ត្រតែមួយមុខទេ សិស្សគួរតែធ្វើការសិក្សាពីស្ថាប័ននៃរបបនោះដែរ ។ ខ្លឹមសារឬព្រឹត្តិការណ៍សំខាន់ៗក្នុងប្រវត្តិសាស្ត្រ ដែលរួមទាំងព្រឹត្តិការណ៍ដែលកើតមានមុននោះទៅទៀត មានមុខងារសំខាន់ធ្វើឲ្យសិស្សយល់ ជាជាងសកម្មភាពនៃតួអង្គសំខាន់តែមួយមុខ ដូចជា អាដូហ្វ អ៊ីត្លែរជាដើម ។

ដើម្បីសិក្សាមុខវិជ្ជា ហូឡូខស សិស្សត្រូវតែចូលរួមក្នុងការសិក្សាឲ្យបានទូលំទូលាយ ។ បញ្ជីឈ្មោះ ថ្ងៃខែ និងទីកន្លែង អាចនឹងជួយបានក្នុងកម្រិតតិចតួចបំផុតក្នុងការស្វែងយល់ពីព្រឹត្តការណ៍ប្រវត្តិសាស្ត្រផ្សេងៗ ។ ជាងនេះទៅទៀត បាបារ៉ា ស៊ែន (១៩៩៨) ឲ្យពួកយើងប្រុងប្រយ័ត្នចៀសវាងចំណុចបីយ៉ាង គឺ ការប្រើប្រាស់ការគិតបច្ចុប្បន្នទៅបកស្រាយអតីតកាល ការរៀបរាប់តែផ្នែកខ្លះនៃរឿងរ៉ាវដែលនៅមានភាពចម្រូងចម្រាស និងមើលស្រាលសមត្ថភាពសិស្សក្នុងការស្វែងយល់ពីភាពស្មុគស្មាញ និងភាពមិនច្បាស់លាស់នៃប្រវត្តិសាស្ត្រ ។ ទាំងសៀវភៅណែនាំនៅសារមន្ទីរនៃការចងចាំ ហូឡូខស និងការសិក្សាទៅលើការព្យាយាមយល់ពីស្ថានភាព និងអារម្មណ៍តួអង្គប្រវត្តិសាស្ត្រ (Research on historical empathy) បានផ្តល់ឲ្យយើងនូវគន្លឹះដែលអាចដោះស្រាយនូវបញ្ហាខាងលើ និងអាចជួយឲ្យសិស្សចាប់ផ្តើមពិចារណាទៅលើទស្សនៈចម្រុះ ដោយមិនបញ្ចូលទស្សនៈផ្ទាល់ខ្លួន ឬការរើសអើង នៅពេលដែលសិស្សព្យាយាមស្វែងយល់ និងបកស្រាយនូវភាពប្លែកៗ និងភាពស្រពេចស្រពិលរបស់ប្រវត្តិហូឡូខស ។

ជាធម្មតា ការគិតពិចារណាបែបប្រវត្តិសាស្ត្រ(Historical thinking) និងការព្យាយាមស្វែងយល់ពីស្ថានភាពនិងអារម្មណ៍តួអង្គប្រវត្តិសាស្ត្រ (Historical Empathy) ច្រើនដោះស្រាយបានចំណុចមួយចំនួន ដូចជា ខ្លឹមសារ ប្រភពប្រវត្តិ ភាពលម្អៀង ភាពមិនស៊ីគ្នានៃសាច់រឿង និងភាពមិន

ច្បាស់លាស់នៃសេចក្តីសន្និដ្ឋាន ។ ពេលដែលយើងធ្វើការភ្ជាប់ដោយផ្ទាល់នូវទំនាក់ទំនង រវាងការពិចារណាបែបប្រវត្តិសាស្រ្ត និងគុណវិបត្តិនៅក្នុងសេចក្តីណែនាំកម្មវិធីសិក្សា យើងទទួលស្គាល់ថា អ្នកស្រាវជ្រាវប្រវត្តិសាស្រ្តដើរតួនាទីយ៉ាងសំខាន់ ក្នុងការពិចារណាទៅលើខ្លឹមសារ តម្លៃ និងសុពលភាពនៃប្រភព ។ ដោយផ្អែកលើការអះអាងខាងលើ យើងសង្កេតឃើញថា ការសិក្សា និងការបង្រៀនប្រវត្តិសាស្រ្តត្រូវតែពឹងផ្អែកទៅលើភាពត្រឹមត្រូវ និងខ្លឹមសាររបស់ប្រវត្តិសាស្រ្ត ។ ការធ្វើឲ្យថ្ងៃខែ ទីកន្លែង និងពេលវេលា ព្រមទាំងឈ្មោះរបស់តួអង្គក្នុងប្រវត្តិសាស្រ្តមានភាពត្រឹមត្រូវ គឺជាតម្រូវការទីមួយក្នុងការបកស្រាយអតីតកាលឲ្យមានសុក្រឹតភាព ។ ជំហានបន្ទាប់មកទៀតគឺការបញ្ចូលនូវព័ត៌មានខ្លឹមចូលទៅក្នុងការបកស្រាយនោះ ដើម្បីលាតត្រដាងឲ្យកាន់តែច្បាស់ «តើមានរឿងអ្វីកើតឡើងខ្លះ» នៅក្នុងប្រវត្តិសាស្រ្ត ។ ដើម្បីពិពណ៌នាព្រឹត្តិការណ៍ប្រវត្តិសាស្រ្តឲ្យបានត្រឹមត្រូវ អ្នកប្រវត្តិសាស្រ្តត្រូវតែដាក់ទម្ងន់ទៅលើធាតុផ្សំ ទាំងនោះ ។ បើអ៊ីចឹងតើសិស្សប្រវត្តិសាស្រ្តអាច «ផ្គុំ» ធាតុទាំងនោះបានយ៉ាងដូចម្តេច?

[....]

សៀវភៅណែនាំសម្រាប់ការបង្រៀនប្រវត្តិសាស្រ្តហូឡូខស (ផាសិន និងថតថិន ១៩៩៣) រៀបរៀងដោយ *សារមន្ទីរនៃការចងចាំហូឡូខស* បំពេញបន្ថែមនូវការសិក្សាស្រាវជ្រាវអំពីការពិចារណា និងការស្វែងយល់ពីស្ថានភាពនិងអារម្មណ៍របស់តួអង្គក្នុងប្រវត្តិសាស្រ្ត ។ [....] សៀវភៅណែនាំនេះរួមបញ្ចូលនូវវិធីសាស្រ្ត១៨យ៉ាង ដើម្បីដោះស្រាយកង្វល់ដែលលើកឡើងដោយមតិរិះគន់ចេញពីឯកសារមួយចំនួន (សូមមើល រីលី ២០០១) ។ វិធីសាស្រ្តទាំង១៨ចំណុចមានដូចខាងក្រោម

- កំណត់និយមន័យពាក្យ “ហូឡូខស”
- ចៀសវាងការប្រៀបធៀបទំហំនៃការឈឺចាប់
- ចៀសវាងនូវការឆ្លើយចម្លើយដែលមានភាពសាមញ្ញ ទៅនឹងសំណួរប្រវត្តិសាស្រ្តដែលមានលក្ខណៈស្មុគស្មាញ
- មិនមែនដោយសាររឿងនេះធ្លាប់បានកើតឡើង ធ្វើឲ្យរឿងនេះក្លាយជារឿងដែលមិនអាចគេចផុតនោះទេ
- ព្យាយាមប្រើប្រាស់ភាសាដែលមានលក្ខណៈច្បាស់លាស់ (ឧទាហរណ៍ “ជនជាតិអាល្លឺម៉ង់ ទាំងអស់គឺជាឃាតករ” )
- ធ្វើការបែងចែកប្រភពព័ត៌មានឲ្យដាច់ពីគ្នា ។
- ចៀសវាងការពិពណ៌នាដោយច្បោលៗ ពុំមានមូលដ្ឋានច្បាស់លាស់

- *ចៀសវាងការបញ្ចូលមនោសញ្ចេតនាទៅក្នុងប្រវត្តិសាស្ត្រដើម្បីឲ្យសិស្សចូលចិត្ត ។*
- *ធ្វើឲ្យប្រវត្តិសាស្ត្រស្របទៅតាមបរិបទដែលអ្នកកំពុងបង្រៀន*
- *បកប្រែតួលេខឲ្យទៅជាមនុស្ស*
- *យកចិត្តទុកដាក់លើសាច់រឿងសរសេរប្រុសម្ល៉ង*
- *ធ្វើការកត់សម្គាល់ទស្សនៈរបស់អ្នកដែលផ្តល់ជាពត៌មានដល់ការសិក្សាហ្វូឡូខស*
- *ធ្វើការជ្រើសរើសសកម្មភាពសិក្សាដែលមានលក្ខណៈសមរម្យ*
- *ជំរុញឲ្យដល់គោលដៅនៃគម្រោងមេរៀនរបស់អ្នក ។*

*(ដាសិន និង ថតចិន ១៩៩៣)*

*ដូច្នេះ ដើម្បីរៀបរៀងមេរៀនហ្វូឡូខស យើងអាចបញ្ចូលចំណុចខ្លះក្នុងចំណោមចំណុចទាំង១៨ ខាងលើ និងចំណុចដទៃទៀតនៅក្នុងអត្ថបទ “ការពិភាក្សាពីលទ្ធភាពក្នុងការស្វែងយល់ពីស្ថានភាព នៅក្នុងហេតុការណ៍ប្រវត្តិសាស្ត្រ” សរសេរដោយ ដាវីស និងអ្នកនិពន្ធផ្សេងៗ ក្នុងឆ្នាំ២០០១ ជាពិសេស គឺខ្លឹមសារនិងកាលប្បវត្តិ ភ័ស្តុតាង រួមបញ្ចូលទាំងការបកស្រាយរបស់អ្នកស្រាវជ្រាវផ្សេងៗទៀត ។ យើងក៏អាចបញ្ចូល ទស្សនៈរបស់តួអង្គប្រវត្តិសាស្ត្រ ព្រមទាំងការបង្កើតរបៀបពិពណ៌នារឿងរ៉ាវ ដែលតាមរយៈនេះយើងអាចទាញយកការសន្និដ្ឋានបែបប្រវត្តិសាស្ត្រមួយ ។ ទោះបីជាមិនបានប្រើប្រាស់វិធីសាស្ត្រដែលបានរៀបរាប់ខាងលើ នៅផ្នែកបន្ទាប់ យើងនឹងលើកឡើងនូវកន្លែងសំខាន់ៗមួយចំនួន ។*

## ការវាយតម្លៃទៅលើកម្មវិធីសិក្សាហ្វូឡូខស

*[អ្នកនិពន្ធបានធ្វើការវាយតម្លៃទៅលើកម្មវិធីសិក្សានៅក្នុងរដ្ឋជាច្រើននៅសហរដ្ឋអាមេរិក ។ សម្រាប់សិក្ខាសិលានេះ យើងនឹងសង្កេតមើលតែលើរដ្ឋមួយប៉ុណ្ណោះ គឺរដ្ឋវីជីញ៉ា] ។*

*រដ្ឋវីជីញ៉ា*

[....]

*សេចក្តីផ្តើមរបស់កម្មវិធីសិក្សាគួរតែមានលក្ខណៈសាមញ្ញ ក្នុងការសិក្សាពីប្រវត្តិសាស្ត្រហ្វូឡូខសៈ “សង្គមវិជ្ជាថ្នាក់មធ្យមនិងគ្រូអង់គ្លេស យោងលើរដ្ឋធម្មនុញ្ញអាមេរិក និងស្នាដៃអក្សរសិល្ប៍មួយចំនួនដូចជា សៀវភៅ អានហ្វ្រែង កំណត់ហេតុរបស់ក្មេងស្រីម្នាក់ ដើម្បីដោះស្រាយ*

បញ្ហារើសអើងដែលកំពុងតែកើតមាន និងដើម្បីធ្វើជាមេរៀនសំខាន់ក្នុងការស្វែងយល់ពីចរិតមនុស្ស ព្រមទាំងធ្វើជាឧទាហរណ៍បង្ហាញពីទំនាក់ទំនងទៅវិញទៅមករវាងសកម្មភាពរបស់ប្រជាពលរដ្ឋ និងរដ្ឋាភិបាល ហើយនិងមូលហេតុដែលនាំទៅរកការបំផ្លិចបំផ្លាញនូវសិទ្ធិមនុស្ស» (សេចក្តីផ្តើម) ។ វិធីសាស្ត្រនេះមានមូលហេតុពីរដែលនាំទៅរកបញ្ហា ។ ទីមួយ អត្ថបទប្រវត្តិសាស្ត្រមានការបូកបញ្ចូលនូវប្រធានបទជាច្រើនដែលមានសភាពសើៗ មិនស៊ីជម្រៅ ហើយក្នុងនោះមានប្រវត្តិសាស្ត្រហូឡូខសផងដែរ ។ ចំណុចទីពីរ ទោះជាសៀវភៅកំណត់ហេតុ អាន់ហ្វ្រែង ដើរតួជាស្នាដៃសំខាន់មួយនៅសតវត្សទី២០ ថែមទាំងបានលើកឡើងនូវប្រធានបទសំខាន់ៗទាក់ទងនឹងជីវិតរបស់ណាស៊ីក៏ដោយ សៀវភៅនេះបានបញ្ចប់សាច់រឿងរបស់ខ្លួននៅមុនពេលមានការបញ្ជូនមនុស្សចេញពីប្រទេស ។ ប្រសិនបើសិស្សប្រើប្រាស់តែសៀវភៅរៀននិងកំណត់ហេតុនេះ ពួកគេនឹងខកខានមិនបានទទួលនូវព័ត៌មានដែលសម្បូរទៅដោយខ្លឹមសារនិងទស្សនៈជុំវិញជីវិតនេះ ។

ការពិភាក្សាពីពេលវេលានៅក្នុងសៀវភៅណែនាំនាំឲ្យឃើញថាកំណត់ត្រាប្រវត្តិសាស្ត្រដែលមិនត្រឹមត្រូវពិតជាមានពិតប្រាកដ ។ មតិមួយបានលើកឡើងថា សកម្មភាពគំរូមួយគួរតែបញ្ចូលនូវចំណុចដូចខាងក្រោមៈ «តើឪពុកម្តាយរបស់អ្នកមានអាយុប៉ុន្មាននៅឆ្នាំ១៩៣៩? តើអ្នកអាយុប៉ុន្មានបើអ្នករស់នៅប្រទេសអាល្លឺម៉ង់ក្នុងឆ្នាំ១៩៣៨ កំឡុងពេលដែលមនុស្សរាប់លាននាក់កំពុងតែត្រូវគេសម្លាប់និងធ្វើទុក្ខបុកម្នេញ?» (ទំព័រ៥) ។ ក្រៅពីភាពមន្ទិលសង្ស័យ សំណួរចុងក្រោយនេះ នៅមានភាពខុសឆ្គងខ្លះដែលនាំឲ្យអ្នកអានយល់ខុស ។ ចំណុចទីមួយ «ជនជាតិជ្វីសរាប់លាននាក់» ដែលអ្នកនិពន្ធសំដៅទៅលើ មិនបានរស់នៅក្នុងប្រទេសអាល្លឺម៉ង់ទេ ។ តាមការពិត «នៅខែមករា ឆ្នាំ១៩៣៣ មុនពេលអ៊ីត្លែរឡើងកាន់អំណាចចំនួនមួយថ្ងៃ ប្រជាជនជ្វីស (...) រាប់ជនជាតិជ្វីសដែលមានចំនួន ៥២២ ០០០ ដោយផ្អែកទៅលើជំនឿសាសនារបស់ក្រុមនោះប៉ុណ្ណោះ ។ (...) ចំណុចទីពីរ បើទោះជាជនជាតិជ្វីស១០ពាន់នាក់ ត្រូវគេធ្វើទុក្ខបុកម្នេញក្នុងឆ្នាំ១៩៣៨ ជនជាតិជ្វីសរាប់លាននាក់មិនត្រូវបានគេសម្លាប់ទេ ។

ការបកស្រាយប្រវត្តិសាស្ត្រហូឡូខសដំបូងដែលមានក្នុងកម្មវិធីសិក្សាចេញមកពីអត្ថបទមួយមានចំណងជើងថា «ហូឡូខស ទស្សនៈវិស័យប្រវត្តិសាស្ត្រ» (”The Holocaust- A Historical Perspective”) ដោយបណ្ឌិត មីរុន ប័រមែន ។ ទោះជា ប័រមែន បានលើកឡើងនូវចំណុចសំខាន់ៗមួយចំនួន (ដូចជា និយមន័យនៃពាក្យ ការរើសអើងជនជាតិជ្វីស (Anti-Semitism) ឥទ្ធិពលនិងសារសំខាន់នៃការរើសអើងជនជាតិជ្វីសកាន់សាសនាគ្រិស្តបុរាណក្នុងគំនិតរបស់ពួកណាស៊ី ចរិតនៃការបំផ្លាញរបស់ណាស៊ីមកលើពួកជ្វីស តួនាទីរបស់អ្នកឃើញហេតុការណ៍ និងការតស៊ូ) ក៏គាត់មិនបានសិក្សាទៅលើចំណុចសំខាន់ៗមួយចំនួនធំដែលរួមមាន ទំនោរប្រវត្តិសាស្ត្រសំខាន់ដែល «រួមគ្នាបង្កើត

ឲ្យមានអំពើប្រល័យពូជសាសន៍ ហូឡូខសៈ ការប្រកាន់ពូជសាសន៍ ការរើសអើងពណ៌សម្បុរ (Social Darwinism) ជាតិនិយម លទ្ធិផ្តាច់ការ ខស្សរាហកម្មនិយម និងសង្គ្រាមសម័យថ្មី» ។ គាត់ក៏មិនបាន ផ្តល់នូវពត៌មានគ្រប់គ្រាន់ ពីកំណើតដំបូងនៃការរើសអើងជនជាតិជ្វីស (Anti-Semitism) និងតួនាទី ជាក់លាក់របស់អ្នកដឹកនាំសាសនាគ្រិស្ត ក្នុងការលើកតម្កើងនិងពន្យុះឲ្យមានជំនឿ និងការអនុវត្តការ រើសអើងជនជាតិជ្វីសកើតមានឡើងក្នុងចំណោមអ្នកកាន់សាសនាជាមួយគ្នានោះទេ ។

ក្នុងចំណោមសកម្មភាពសិក្សានៅក្នុងសៀវភៅណែនាំទាំង៣០ មានតែសកម្មភាពបីប៉ុណ្ណោះ ដែលស៊ីគ្នាទៅនឹងប្រវត្តិសាស្ត្រហូឡូខស[....] ហើយសកម្មភាពទាំងនោះមិនគ្រប់គ្រាន់ដើម្បីជួយសិស្ស ឲ្យយល់ពីខ្លឹមសារ កាលប្បវត្តិ ភ័ស្តុតាង និងទស្សនវិស័យ នោះទេ ។ គ្មានការចាំបាច់ដែលត្រូវត្រួត ពិនិត្យលើប្រភពទេ ។ ជាងនេះទៅទៀត សំណួរមួយចំនួនដូចជា «តើសៀវភៅដែលសរសេរដោយ អ៊ីវ៉ៃរមានចំណងជើងយ៉ាងដូចម្តេច?» មានភាពងាយស្រួលក្នុងការអាន ប៉ុន្តែមិនអាចធ្វើឲ្យសិស្សស្វែង យល់ឲ្យស៊ីជម្រៅពីសារសំខាន់របស់សៀវភៅនេះទេ ។

*(អ្នកនិពន្ធបន្តធ្វើការវិភាគកម្មវិធីសិក្សាផ្សេងៗទៀតដែលបានកាត់ចេញពីអត្ថបទនេះហើយ)*

# ការពិភាក្សានិងសេចក្តីសន្និដ្ឋាន

នៅផ្នែកនេះ យើងនឹងផ្តល់នូវវិធីសាស្ត្រខ្លះក្នុងការពិចារណាទៅលើបញ្ហាដែលកើតមាននៅក្នុង សៀវភៅណែនាំកម្មវិធីសិក្សា ហូឡូខស ដោយធ្វើការពិចារណាទៅលើអត្ថបទរបស់ ដាវីស និងអ្នក និពន្ធផ្សេងៗ (២០០១) *«ការពិភាក្សាពីលទ្ធភាពក្នុងការស្វែងយល់ពីស្ថានភាពនៅក្នុងហេតុការណ៍ ប្រវត្តិសាស្ត្រ»* ដោយក្នុងនោះរួមមានការណែនាំទៅលើព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗ ខ្លឹមសារ និងកាលប្បវត្តិ ភ័ស្តុតាង រួមបញ្ចូលទាំងការបកស្រាយរបស់ប្រវត្តិវិទូផ្សេងទៀត រួមទាំងទស្សនៈរបស់ តួអង្គប្រវត្តិសាស្ត្រ និងការបង្កើតការពិពណ៌នារឿងរ៉ាវ ដែលតាមរយៈវិធីនេះ យើងនឹងអាចទាញយក ការសន្និដ្ឋានមួយ ។ ទាក់ទងទៅនឹងផ្នែកទីមួយ សេចក្តីផ្តើមលើប្រធានបទ ហូឡូខស ត្រូវបានដាក់ឲ្យស្ថិត នៅក្នុងកម្រិតមួយទូលាយដែលរួមបញ្ចូលតួអង្គប្រវត្តិសាស្ត្ររាប់លាននាក់ ។ ជាញឹកញាប់តួអង្គ ទាំងនោះត្រូវគេបែកចេញជាប្រភេទដូចជា ជនដៃដល់ អ្នកផ្សំគំនិត ជនរងគ្រោះ អ្នកឃើញហេតុ- ការណ៍ និងអ្នកជួយសង្គ្រោះ ។ បញ្ហាដែលគ្រូច្រើនជួបប្រទះ គឺការផ្តើមការសិក្សា ហូឡូខស ជាមួយ សំណួរថា *តើរឿងបែបនេះកើតឡើងដោយរបៀបណា?* សំណួរដែលមានលក្ខណៈទូលាយបែបនេះ អាចនាំឲ្យលោកគ្រូអ្នកគ្រូចាកឆ្ងាយចេញពីសំណួរ ហើយផ្តោះទៅពិពណ៌នារឿងរ៉ាវបានតែមួយជ្រុង

ដែលបញ្ហាបែបនេះយើងអាចរកឃើញនៅក្នុងសៀវភៅឬសេចក្តីណែនាំកម្មវិធីសិក្សា ។ ប៉ុន្តែនេះមិនមែនជាបញ្ហានោះទេ ។ ដោយសួរសំណួរដូចជា *តើខ្ញុំត្រូវស្វែងយល់ពីអ្វីខ្លះ?* មុននឹងសួរសំណួរថា *តើរឿងបែបនេះកើតឡើងដោយរបៀបណា?* អ្នកនឹងអាចចាប់ផ្តើម ធ្វើការស្វែងយល់ដោយជ្រើសរើសផ្នែកផ្សេងៗយកមកពិនិត្យ ។

ជាលទ្ធផលគ្រូអាចធ្វើការបញ្ចូលសមាសភាពទីមួយ(សេចក្តីផ្តើមនៃព្រឹត្តការណ៍ប្រវត្តិសាស្ត្រ) ដោយស្នើឲ្យសិស្សបង្កើតនូវបញ្ជីបែងចែកប្រភេទឬខ្លឹមសារដែលអាចជួយគាត់ឲ្យចាប់ផ្តើមរៀបចំព្រឹត្តិការណ៍ឲ្យមានរបៀបតាមកាលប្បវត្តិនិងតាមខ្លឹមសារនៃរឿង ។ ឧទាហរណ៍ សិស្សអាចសួរថា *ហេតុអ្វីទើបជាជនជាតិជ្វីស?* សំណួរនេះត្រូវការឲ្យសិស្សយល់ដឹងពីការរើសអើសជនជាតិជ្វីសនៅក្នុងប្រវត្តិសាស្ត្រ មិនមែនត្រឹមតែរបៀប ណាស៊ី គិតលើជនជាតិជ្វីស ឬក៏ការរើសអើងដែលកើតឡើងនៅសតវត្សទី២០ទេ ។ ដូច្នេះ សំណួរដែលទាក់ទងនឹងហេតុការណ៍ មុនពេលព្រឹត្តិការណ៍ចាប់ផ្តើមដើរតួនាទីសំខាន់នៅក្នុងការស្វែងយល់ប្រវត្តិសាស្ត្រក្នុងលក្ខណៈស៊ីជម្រៅ ។ ហេតុដូចនេះ ចំនួនមនុស្ស ៦ ០០០ ០០០នាក់ គ្មានតម្លៃពិតប្រាកដសម្រាប់ឲ្យសិស្សស្វែងយល់ពីជនជាតិជ្វីស ឬវប្បធម៌របស់ជ្វីស ។ បើសិនជាគ្មានការពិនិត្យមើលទៅលើជីវិតជ្វីសនៅអឺរ៉ុបមុនពេលសង្គ្រាម សិស្សមិនអាចយល់ពីការបាត់បង់ទេ បើសិនជាគ្មានការស្វែងយល់ពីអ្វីដែលបានកើតឡើងពីដំបូងទេ .... ទំនាក់ទំនងរបស់ព្រឹត្តការណ៍មុនពេលដែលប្រវត្តិសាស្ត្រចាប់ផ្តើម នឹងប្រធានបទនេះវាលើសពីគ្រប់គ្រាន់ ដើម្បីបង្កើតនូវការបកស្រាយមួយដែលអាចទុកចិត្តបាន ។

សារសំខាន់នៃខ្លឹមសារ ដែលជាធាតុផ្សំទីពីរ មិនអាចមើលរំលងបានទេ ...... ដើម្បីឲ្យគ្រូអាចបង្រៀនពីខ្លឹមសារបាន គ្រូត្រូវតែជួយសិស្សឲ្យបោះបង់ចោលទម្លាប់ក្នុងការយកការគិតបច្ចុប្បន្ន ទៅបកស្រាយអតីតកាល ។ យើងអាចនិយាយម្យ៉ាងទៀតបានថា ការស្វែងយល់ពីប្រវត្តិសាស្ត្រមិនត្រូវការ ការយល់ព្រមឬការប្រឆាំងនោះទេ ។ ឧទាហរណ៍ នៅពេលដែលសិស្សមានបំណងវាយតម្លៃឬបកស្រាយអារម្មណ៍របស់អ្នកសង្គ្រោះហូឡូខស ដូចជា អូស្ការ ស៊្ហីនល័រ សិស្សតោងពិចារណាទៅលើការពិតមួយគឺ ដំបូងឡើយ ស៊្ហីនល័រ គឺជាអ្នកយកប្រយោជន៍ពីសង្គ្រាម ដោយគាត់បានកេងចំណេញពីលើជនជាតិជ្វីសនៅពេលដែលជ្វីសបានបាត់បង់រោងចក្រ ហើយសុំទិញការងារពីពួកមន្ត្រីណាស៊ី.... ចំណេះដឹងរបស់សិស្សមិនត្រូវការ ទាំងការគាំទ្រការផ្លាស់ប្តូរចិត្តរបស់ ស៊្ហីនដ័រនៅកំឡុងពេលសង្គ្រាម (ពេលដែលគាត់សម្រេចចិត្តសង្គ្រោះពួកជ្វីស) ទាំងការប្រឆាំងនឹងសកម្មភាពកេងយកផលចំណេញរបស់គាត់នៅមុននោះ ។

សមាសធាតុទីបីគឺការពិនិត្យទៅលើភស្តុតាងដែលមានទំហំធំ ។ ជាក់ស្តែង គ្រូមានតួនាទីសំខាន់និងចម្បង ក្នុងការធ្វើឲ្យសិស្សមានឱកាសរៀនសូត្រ.... ប៉ុន្តែចំណង់ចង់ចេះដឹងរបស់គ្រូបង្រៀនផ្នែក

សន្តមវិជ្ជា អាចជាមូលហេតុធ្វើឲ្យគ្រូដឹកនាំសិស្សទៅរកតែភស្តុតាងណាដែលគាំទ្រការយល់ឃើញរបស់គាត់ ធ្វើឲ្យសិស្ស«យល់ខុស» ។ (...) ក្នុងការសិក្សារបស់គាត់ (១៩៩៨) បាបារ៉ា ស៊ីន បានប្រើប្រាស់វិធីសាស្ត្រមួយគឺ ការព្យាយាមស្វែងយល់ពីស្ថានភាពនិងអារម្មណ៍អ្នកនៅក្នុងហេតុការណ៍ប្រវត្តិសាស្ត្រ (Historical Empathy) ធ្វើជាគំនិតដើម្បីស្វែងយល់ពីបទពិសោធន៍របស់ស្ត្រីដែលមិនមែនជាជនជាតិជ្វីស និងសកម្មភាពរបស់ស្ត្រីទាំងនោះនៅក្នុងជំនាន់ ស៊ើតរ៉ៃក (The Third Reich) ។ ស៊ីន ចង់.... វិភាគតឹកតាងដែលជំរុញឲ្យស្ត្រី(ជនជាតិអាល្លឺម៉ង់) ទាំងនោះធ្វើដូចអ្វីដែលគេបានធ្វើ ។ គាត់រកឃើញថា ទស្សនៈ (Historical Empathy) ដែលលើកឡើងនៅពេលនេះ នាំឲ្យគាត់យល់កាន់តែច្បាស់ពីរបៀប និងមូលហេតុដែលស្ត្រីជនជាតិអាល្លឺម៉ង់ទាំងនោះធ្វើអំពើដូចអ្វីដែលស្ត្រីទាំងនោះបានធ្វើ ។ ទោះជាយ៉ាងនេះក៏ដោយ ស៊ីន នៅតែអាចបញ្ចូលទស្សនៈផ្ទាល់ខ្លួនដើម្បីពន្យល់ពី ហូឡូខសនិងជនដៃដល់នៃរបបនោះដែរ ។

.... ប្រសិនបើការយល់ដឹងរបស់សិស្សអំពីហូឡូខសឬព្រឹត្តការណ៍ប្រវត្តិសាស្ត្រដទៃទៀតពឹងផ្អែកទៅលើភស្តុតាងដែលសិស្សមាន ហើយប្រសិនបើគ្រូធ្វើការជ្រើសរើសប្រភព នៃតឹកតាងទាំងនោះ លម្អៀងដោយមិនដឹងខ្លួន តើបញ្ហានេះនឹងទៅជាដូចម្ដេចទៅវិញ? ... ប្រសិនបើគ្រូអាចប៉ាន់ស្មានពីជំហររបស់ខ្លួនបាន ឧទាហរណ៍ដូចជា ជំហរក្នុងការស្វែងយល់ពីប្រវត្តិសាស្ត្រហូឡូខស មុនពេលដែលពួកគាត់ចាប់ផ្ដើមធ្វើការជ្រើសរើសភស្តុតាងនោះ គឺជាការប្រសើរបំផុត ។

ចុងក្រោយ សមាសធាតុទីបួន ការបង្កើតនូវការពិពណ៌នាហេតុការណ៍ប្រវត្តិសាស្ត្រ ដោយទាញការសន្និដ្ឋានចេញពីការវិភាគទៅលើតឹកតាង អាចបង្កើតនូវចម្ងល់ដើម្បីធ្វើការស្រាវជ្រាវបន្តទៀតជាជាងការការផ្ដល់នូវសេចក្ដីសន្និដ្ឋាន... ។ ករណីនេះប្រសិនបើសិស្សពិនិត្យតែលើសកម្មភាពរបស់អាដូហ្វ អ៊ីត្លែរ កំឡុងពេលដែលគាត់កាន់អំណាច នោះសិស្សនឹងខកខានក្នុងការស្វែងយល់ពីហេតុការណ៍សំខាន់ៗមុនពេលគាត់ឡើងកាន់អំណាច រហូតដល់ដំណាក់កាលនៃការរើសអើងជនជាតិជ្វីសនៅសតវត្សទី២០ ដែលជាមូលដ្ឋានសំខាន់នាំឲ្យមានការសម្លាប់រង្គាលជនជាតិជ្វីស ។ ការធ្វើសេចក្ដីសន្និដ្ឋានថា អ៊ីត្លែរ ជាអ្នកទទួលខុសត្រូវទៅលើអំពើដែលកើតមាននៅ ហូឡូខសតែមួយមុខ ពិតធ្វើឲ្យតួនាទីរបស់តួអង្គសំខាន់ផ្សេងៗទៀតលែងមានសារសំខាន់ ក្នុងនោះ រួមមាន ហ្វ្រែងលីន រូសវែល (Franklin Roosevelt) បរាជ័យរបស់ អ៊ីវ៉ាន (សន្និសីទនៅរដូវក្ដៅឆ្នាំ១៩៣៨ ក្នុងគោលបំណងដោះស្រាយការកើនឡើងនៃបញ្ហាជនភៀសខ្លួនដែលជាផលវិបាក[....]ចេញពីនយោបាយប្រឆាំងនឹងជនជាតិជ្វីសរបស់ពួកណាស៊ី) ការរីតត្បិតការគ្រប់គ្រងបែបទំនើបនិយម, ការឈានទៅមុខនៃបច្ចេកវិទ្យា, និងប្រវត្តិសាស្ត្រផ្ទាល់តែម្ដង ។

ហេតុនេះ ដើម្បីស្វែងយល់ពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ហូឡូខស យើងគោងធ្វើការចាប់ផ្តើម សួរសំណួរដែលមានលក្ខណៈទូលាយនិងបើកចំហ ដែលអាចជួយយើងបែងចែកប្រភេទនៃការអង្កេត និងជំរុញឲ្យយើងវេញបញ្ចូលគ្នានូវហេតុការណ៍មុនពេលព្រឹត្តិការណ៍ប្រវត្តិសាស្ត្រចាប់ផ្តើម ដំណើរ ប្រព្រឹត្តទៅនៃប្រវត្តិសាស្ត្រ ព្រឹត្តិការណ៍នៅកំឡុងពេលនោះ ព្រមទាំងសកម្មភាពរបស់តួអង្គសំខាន់ៗ និងការប្រមូលផ្តុំនៃតួអង្គទាំងនោះ ។ លទ្ធផលចុងក្រោយនៃដំណើរការនេះនឹងបង្ហាញថា យើងបាន ពិចារណាទៅលើ ខ្លឹមសារ គឹកគាង និងជំហររបស់យើងក្នុងការវេញបញ្ចូលគ្នាដើម្បីពន្យល់អំពី អតីតកាល ។ លទ្ធផលនេះគួរតែបង្ហាញផងដែរថា ការផ្សារភ្ជាប់ទៅនឹងវិធីសាស្ត្រ ឬសៀវភៅណែនាំ អាចធ្វើឲ្យយើងឃើញនូវសកម្មភាពរបស់តួអង្គប្រវត្តិសាស្ត្រ ដោយគ្មានការគាំទ្រ ឬការប្រឆាំង ព្រមទាំងអាចឲ្យយើងទាញចេញនូវការបកស្រាយមួយសមហេតុសមផល ។ លទ្ធផលនេះធ្វើឲ្យយើង ដឹងថា ការមិនរាប់បញ្ចូលនូវប្រភពនៃគឹកគាង អាចជះឥទ្ធិពលទៅលើការបកស្រាយរបស់យើង ។

ចប់